# ព្រះរាជក្រម

នស/រកម/០២០៨/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE

# ច្បាប់

# ស្តីពី

# តំបន់ការពារធម្មជាតិ

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

3/38

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ ។

គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព ។

**មាត្រា ២.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តនៅតំបន់ការពារធម្មជាតិ ដែលកំណត់ដោយបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់បម្រុងជីវមណ្ឌលបឹងទន្លេសាប លេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០១ និងលិខិតបទដ្ឋានផ្សេងទៀត ។

**មាត្រា ៣.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា ៤.-**

ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា ២ នៃច្បាប់នេះ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

ក្រសួងបរិស្ថានមានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលការពារនិងអភិរក្សធម្មជាតិក្នុងតំបន់ការពារធម្មជាតិនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋានជនជាតិដើមភាគតិច និងសាធារណជន ដើម្បីចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តរភាព ។

**មាត្រា ៥.-**

រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវបំពេញភារកិច្ចសំខាន់ៗដូចតទៅ :

១-រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

២-លើកការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ តាមតម្រូវការរបស់រាជរដ្ឋាភិបាល ឬ អនុលោមទៅតាមអនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ

៣-រៀបចំបទប្បញ្ញត្តិ លិខិតបទដ្ឋាននានា ដើម្បីអនុវត្តច្បាប់នេះឱ្យ មានប្រសិទ្ធភាព

៤-ចាត់វិធានការដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ

៥-អប់រំផ្សព្វផ្សាយដល់សាធារណជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ

៦-រៀបចំកិច្ចព្រមព្រៀងស្ដីពីកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ ។

**មាត្រា ៦.-**

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានសិទ្ធិ និងភារកិច្ចសំខាន់ៗដូចខាងក្រោម :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១-យាមល្បាត ត្រួតពិនិត្យជាប្រចាំ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ

២-ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗ ដែលកំណត់ដោយច្បាប់នេះ

៣-មានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ

៤-ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាកក្នុងតំបន់ការពារធម្មជាតិ

៥-ធ្វើការអប់រំផ្សព្វផ្សាយ និងសម្របសម្រួលជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិចក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ ។

សិទ្ធិនិងភារកិច្ចលំអិតរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៣
## ការរៀបចំកែប្រែតំបន់ការពារធម្មជាតិ

**មាត្រា ៧.-**

តំបន់ការពារធម្មជាតិ ត្រូវចែកចេញជាប្រភេទដូចខាងក្រោម :

១-តំបន់ឧទ្យានជាតិ

២-តំបន់ដែនជម្រកសត្វព្រៃ

៣-តំបន់ការពារទេសភាព

៤-តំបន់ប្រើប្រាស់ច្រើនយ៉ាង

៥-តំបន់រ៉ាមសារ

៦-តំបន់ស្នូលនៃឋបនីយជីវមណ្ឌល

៧-តំបន់បេតិកភណ្ឌធម្មជាតិ

៨-តំបន់ឧទ្យានជាតិសមុទ្រ ។

តំបន់ការពារធម្មជាតិខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។